**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសុខាភិបាល

លេខ..២៧៣..ក្រប../អបស

# ប្រកាស

# ស្តីពី

# ស្លាកបម្រាមនៃការហាមការជក់ឬការបង្ហាញផ្សព្វផ្សាយផលិតផលថ្នាំជក់

••••

# រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួលបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ចុះថ្ងៃទី២៤ ខែមករាឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសុខាភិបាល

-បានឃើញព្រះរាជក្រមលេខនស/រកម/០៥១៥/០០៤ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ ២០១៥ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពី ការត្រួតពិនិត្យផលិតផលថ្នាំជក់

- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល

- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី១៦ ខែមិនា ឆ្នាំ២០១៦ ស្តីពី វិធានការហាមការជក់ ឬការបង្ហុយផ្សែងផលិតផលថ្នាំជក់នៅកន្លែងធ្វើការ ឬ កន្លែងសាធារណៈ

- យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល



ទីស្តីការក្រសួងសុខាភិបាល មហាវិថីលេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងបង្ហាញកន្លែងហាមជក់ ឬបង្ហុយផ្សែងផលិតផលថ្នាំជក់ដើម្បីការពារសុខុមាលភាពរបស់ប្រជាជនពីផលប៉ះពាល់នៃផលិតផលថ្នាំជក់។

**ប្រការ២.-**

ប្រកាសនេះមានគោលដៅកំណត់គំរូ និងនីតិវិធីនៃការដាក់ស្លាកបម្រាមនៃការហាមការជក់ ឬការបង្ហុយផ្សែងផលិតផលថ្នាំជក់នៅតាមទីកន្លែងធ្វើការ ឬទីកន្លែងសាធារណៈដែលហាមជក់។

**ប្រការ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះការដាក់ស្លាកបម្រាមនៃការហាមការជក់ ឬការបង្ហុយផ្សែងផលិតផលថ្នាំជក់ នៅទីកន្លែងហាមជក់ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤.-**

ស្លាកបម្រាមអំពីការហាមការជក់ ឬការបង្ហុយផ្សែងផលិតផលថ្នាំជក់ត្រូវតែជាសារសរសេរជាភាសាខ្មែរ និងភាសាអង់គ្លេស និងត្រូវអមដោយសញ្ញាបម្រាម។

ស្លាកបម្រាមត្រូវសរសេរថា "ហាមជក់បារី" "NO SMOKING" អមជាមួយនឹងសញ្ញាបម្រាមដែលមានរូបភាពបារីមួយដើមនៅក្នុងរង្វង់ក្រហម និងមានបន្ទាត់ក្រហមមួយគូសចំអង្កត់ផ្ចិតបញ្ឆិតពីខាងលើនៃផ្នែកខាងឆ្វេងមកខាងក្រោមផ្នែកខាងស្តាំដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ។

ស្លាកបម្រាមអំពីការហាមការជក់ ឬការបង្ហុយផ្សែងផលិតផលថ្នាំជក់ត្រូវមានទំហំអប្បបរិមា៖ សម្រាប់បរិវេណ ទំហំ ៣៤១០០ សង់ទីម៉ែត្រការ៉េ (បណ្តោយ ២២០ សង់ទីម៉ែត្រ និងទទឹង១៥៥សង់ទីម៉ែត្រ) សម្រាប់កន្លែងធ្វើការ កន្លែងអគារសាធារណៈ៖ បិទបាំងទំហំ ៦០០សង់ទីម៉ែត្រការ៉េ (បណ្តោយ៣០សង់ទីម៉ែត្រនិងទទឹង២០សង់ទីម៉ែត្រ) និងសម្រាប់មធ្យោបាយដឹកជញ្ជូនសាធារណៈ ទំហំ ២០០សង់ទីម៉ែត្រការ៉េ (បណ្តោយ ២៤សង់ទីម៉ែត្រ និងទទឹង១២សង់ទីម៉ែត្រ) ។

**ប្រការ៥.-**

អ្នកគ្រប់គ្រង ឬម្ចាស់កន្លែងធ្វើការ ឬម្ចាស់កន្លែងសាធារណៈត្រូវបិទផ្សាយ ឬដាក់ស្លាកបម្រាមដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសនេះនៅកន្លែងដែលសាធារណជនអាចមើលឃើញច្បាស់ជាអាទិ៍ កន្លែងចេញចូល កន្លែងទទួលភ្ញៀវ បន្ទប់ទឹក។

**ប្រការ៦.-**

អ្នកគ្រប់គ្រង ឬម្ចាស់កន្លែងធ្វើការ ឬម្ចាស់កន្លែងសាធារណៈអាចបោះពុម្ព ឬផលិតចែកចាយស្លាកបម្រាមនៃការហាមការជក់ ឬការបង្អួយផ្សែងផលិតផលថ្នាំជក់ទៅតាមគំរូដូចមានក្នុងឧបសម្ព័ន្ធ។

**ប្រការ៧.-**

បុគ្គលណាដែលរំលោភបទប្បញ្ញត្តិនៃប្រកាសនេះត្រូវទទួលពិន័យតាមច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ អនុក្រឹត្យស្តីពី វិធានការហាមការជក់ឬការបង្អួយផ្សែងផលិតផលថ្នាំជក់នៅកន្លែងធ្វើការឬកន្លែងសាធារណៈ។

**ប្រការ៨.-**

បទប្បញ្ញត្តិណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៩.-**

អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានអង្គភាព ប្រធានមន្ទីរសុខាភិបាលរាជធានី-ខេត្ត ក្រោមឱវាទក្រសួងសុខាភិបាលដែលពាក់ព័ន្ធត្រូវអនុវត្តតាមប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០១៦

**ម៉ម ប៊ុនហេង**

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង និងស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យក្រសួងសុខាភិបាល
- សាលារាជធានី-ខេត្ត
- គណៈកម្មការអន្តរក្រសួងដើម្បីការអប់រំនិងកាត់បន្ថយការប្រើប្រាស់ថ្នាំជក់
- ដូច ប្រការ៩
- ឯកសារ-កាលប្បវត្តិ

# ហាមជក់បារី
# NO SMOKING



យោងអនុក្រឹត្យលេខ ៤៣ អនក្រ.បក ស្ដីពី
វិធានការហាមជក់ ឬបង្ហុយផ្សែងផលិតផល
ថ្នាំជក់នៅកន្លែងធ្វើការ ឬកន្លែងសាធារណៈ

**ជនណាជក់បារីនៅកន្លែងហាមឃាត់ត្រូវពិន័យ 20 000 រៀល**

**PENALTY APPLIED**